# «ខ្ញុំ» និង «អញ» (ភាគ១)

នាពេលកន្លងមក AMS **អរិយធម៌ខ្មែរ** បានចុះផ្សាយរួចហើយនូវអត្ថបទស្តីពី « "ខ្ញុំ" ក្នុងសិលាចារឹកខ្មែរ» ដោយលើកទឡ្ហីករណ៍ មកជម្រះមន្ទិល និងបដិសេធទស្សនៈដែលអ្នកស្រាវជ្រាវមួយចំនួននាពេលកន្លងមក តែងយល់ថាពាក្យ «ខ្ញុំ» ត្រូវនឹងពាក្យបារាំងថា «Esclave» និងអង់គ្លេសថា «Slave» ដែលសំដៅដល់ទាសករ។[១] នៅក្នុងអត្ថបទនេះ យើងនឹងបន្តពិនិត្យមើលលើបម្រែបម្រួលនៃការប្រើប្រាស់ពាក្យ «ខ្ញុំ» និង «អញ» ព្រមទាំងពិនិត្យលើប្រភពពាក្យទាំងពីរនេះ តាមរយៈឯកសារសិលាចារឹកភាសាខ្មែរបុរាណ និងឯកសារដទៃទៀត។

មនុស្សខ្មែរជាទូទៅ យល់គ្រប់គ្នាទៅហើយថាពាក្យ «ខ្ញុំ» និង «អញ» គឺជាពាក្យប្រើសម្រាប់ហៅខ្លួនឯង ឬហៅតាមរបៀបវេយ្យាករណ៍ថាជាសព្វនាមបុរិស បុរសទី១ ដូចគ្នា។ ដែលខុសគ្នានោះ គេបានធ្វើបន្ទែកពាក្យទាំងពីរនេះដោយចាត់ទុកថាពាក្យ «ខ្ញុំ» ជាពាក្យសមរម្យ រម្យទម រាបសា សម្រាប់អ្នកផងទៅប្រើក៏បាន ឬសម្រាប់អ្នកមានវ័យតិច ឋានៈទាប ប្រើជាមួយអ្នកមានវ័យច្រើនជាង ឋានៈខ្ពស់ជាង។ ចំណែកឯពាក្យ «អញ» បើយើងមើលតាមវចនានុក្រមខ្មែរយើងឃើញថា ពាក្យនេះចាត់ទុកជាអញ្ញត្រសព្ទនៃពាក្យ «ខ្ញុំ» ជាសម្តីកូនក្មេងនិយាយរកគ្នា អ្នកមានវ័យឬឋានៈស្មើគ្នានិយាយរកគ្នាដោយស្និទ្ធស្នាល អ្នកមានវ័យឬឋានៈខ្ពស់ជាង និយាយទៅអ្នកមានវ័យឬឋានៈទាបជាងដោយស្និទ្ធស្នាល។[២] កាលបើនិយាយជាសាធារណ៍ឬជាផ្លូវការ ខ្មែរយើងពុំសូវឬពុំឱ្យតម្លៃតែម្តង លើការប្រើពាក្យ «អញ» នេះឡើយ។

តាមរយៈភស្តុតាងសិលាចារឹក ពាក្យ «ខ្ញុំ» សម័យមុនអង្គរ មានសំណេរជា «ក្ញុំ»[៣]

---

[១] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/2493។

[២] វចនានុក្រមខ្មែរ (ភាគ២) ១៩៦៨: ១១៩៨។

[៣] នាសម័យនោះ តួសញ្ញាជើង «ញ» គឺប្រើជារូបរាងតួ «ញ» ទាំងមូលដាក់នៅខាងក្រោមព្យញ្ជនៈ «ក» តែម្តង ដែលពុម្ពអក្សរបច្ចុប្បន្នពុំអាចវាយចេញរូបរាងដូច្នោះបាន។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

(K. ៦៖ ប.៣ និង ៩; K. ១៨៖ ប.៦, ១២, ២១ និង ៣០...) «ក្ញុំមិ» (; K. ១៨៖ ប.២; K. ៣៨៖ ប. ៧...) «ក្ញុមិ» (K. ៤២៣៖ ប.១) «ក្ញុម្ម» (K. ៥៤៖ ប.៧) «ក្ញុំ»[៤] (K. ៤៥១ត្បូង៖ ប.២ និង ១១) «ក្ញោំ»[៥] (K. ៥៦១៖ ប.២៣) និង «ក្យុំ» (K. ៣៨៨គ៖ ប.៦)[៦]។ មកដល់ដើមសម័យអង្គរ សំណេរ «ក្ញុំ» នៅតែបន្តប្រើ ជាពិសេសនៅដើមសម័យអង្គរ[៧] និងបន្ទាប់មកទៀតគឺសំណេរ «ខ្ញុំ ខ្ញុំមិ ខ្ញុំម ខ្ញុមិ ខញុំ» គឺមានការផ្លាស់ប្តូរពីការកត់ត្រាដោយអក្សរ «ក» មកជាអក្សរ «ខ» វិញ[៨]។ លុះរហូតមកដល់សម័យកណ្តាល សំណេរពាក្យនេះ ពុំសូវជាខុសប្លែកអ្វីពីសម័យអង្គរឡើយ ដែលមានសំណេរដូចជា «ខ្ញុំ ខ្ញុំម ខ្ញុំម្ម ខ្ញុម ខ្ញុំ ខ្ញុំម ខ្ញម»[៩]។

អ្នកស្រាវជ្រាវខាងភាសាខ្មែរបុរាណ បានពន្យល់ពាក្យ «ក្ញុំ» ថាមកពីពាក្យឫស «*ញុំ/ញុមិ» និងផ្នត់ដើម [ក-][១០]។ លោកបណ្ឌិត ឡុង សៀម បានពន្យល់ថា ពាក្យ «ញុមិ» នៅក្នុងភាសាមនបុរាណ ប្រែថា «អ្នកផ្គត់ផ្គង់ ឬ អ្នកបម្រើសេចក្តីត្រូវការរបស់លោកសង្ឃនៅក្នុងវត្តអារាម»[១១]។ នៅក្នុងវចនានុក្រមសិលាចារឹកមន បានពន្យល់ថា «ញុមិ/ញូមិ» ជាពាក្យដាក់នៅខាងដើមនរនាមដែលជាក្រុមអ្នកបម្រើតាមវត្តអារាម[១២]។ នៅក្នុងន័យនេះហើយ ដែលលោកបណ្ឌិត ឡុង សៀម បានបន្តពន្យល់ថាពាក្យមនមួយនេះ ក៏ពុំមានន័យ

---

៤ នៅក្នុងសិលាចារឹកមានសំណេរជា «ត្ញុំ» ដែលជាអ្នកចារ ចារច្រឡំ។ ក្នុងករណីនេះ យើងពុំច្បាស់ថាអ្នកចារ ចារភ្លេចសញ្ញាស្រៈ «ុ» ដែរឬទេ ព្រោះសំណេរនេះ យើងប្រទះឃើញពីរដងគត់នៅក្នុងសិលាចារឹកតែមួយ ដែលសំណេរទីពីរសរសេរជា «ត្ញ» ដែលបង្ហាញពីកំហុសនៃអ្នកចារសិលាចារឹកមួយនេះ។

៥ ពាក្យនេះនៅលើក្រដាសផ្តិតសិលាចារឹក ពុំសូវច្បាស់ឡើយ ខណៈសំណេរពាក្យនេះនៅត្រង់ចំណុចផ្សេងទៀតសរសេរជា «ក្ញុំ» ដូចសិលាចារឹកដទៃទៀតដែរ។

៦ Jenner 2009[a]: 63។

៧ យ៉ាងហោចណាស់គេរកឃើញសំណេរនេះចំនួន១៧ដងនាសម័យអង្គរ ដែលសិលាចារឹកចាស់ជាងគេនៅសម័យអង្គរមានពាក្យនេះ គឺសិលាចារឹកវត្តសសរមួយរយ K. ១២៤ ចារនៅគ្រិស្តសករាជឆ្នាំ៨០៣។

៨ សូមអាន Jenner 2009[b]: 65។

៩ សូមអាន Jenner 2011: 34។

១០ ឡុង សៀម ២០០០: ១៣៤; Jenner 2009[a]: 63, 2009[b]: 65។

១១ ឡុង សៀម ២០០០: 2G។

១២ Nai Tun Way 2012: 391។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ខុសប្លែកប៉ុន្មានពីពាក្យខ្មែរសម័យទំនើបថា «ញោម» ដែលមានន័យថាពុទ្ធបរិស័ទដើងវត្ត ហើយក៏ជាឧបដ្ឋាកឬអ្នកផ្គត់ផ្គង់វត្តអារាម[១៣]។ តាមអ្វីដែលបានពន្យល់ខាងលើនេះ យើងគួរចាប់អារម្មណ៍បន្តិចលើពាក្យ «ខ្ញុំ» ដែលយើងនិយាយជាសាមញ្ញទូទៅស្ទើរគ្រប់គ្នាថា «ញុំ»[១៤] នោះ យើងអាចពិនិត្យបានតាមរយៈទិដ្ឋភាពពីរយ៉ាង។ ករណីទីមួយ សម្ដីដែលយើងនិយាយជា «ញុំ» អាចជាពាក្យដែលយើងនិយាយក្នុងទម្រង់ជាឫសរបស់ពាក្យ «ខ្ញុំ» ចំណែកឯករណីទីពីរ គឺជាការលេបសូរខាងដើមនៃពាក្យ «ខ្ញុំ» ដែលសង្កេតឃើញមានដូចករណីពាក្យ ផ្សារ > *សារ[១៥], អង្គុយ > *ង្គុយ > *គុយ[១៦], ស្ទូ > *ទ្បូ, ស្ទា > *ទ្បា, ស្ទាប់ > *ទ្បាប់, ស្ទែង > *ទ្បែង[១៧], ផ្ទះ > *ទះ ។ល។ ក្នុងករណីដែលស្រៈ ព្យញ្ជនៈ ឬព្យាង្គដើមពាក្យបានបាត់បង់នៅពេលបន្លឺសូរ នៅក្នុងភាសាវិទ្យាហៅថា «បុព្វលុប/អាទិលុប»[១៨]។

តាមរយៈអត្ថបទសិលាចារឹកភាសាខ្មែរសម័យមុនអង្គរនិងអង្គរ ពាក្យ «ខ្ញុំ» ពុំប្រើជាពាក្យសម្រាប់ហៅខ្លួនឯង ឬសព្វនាមបុរិសបុរសទី១ នោះឡើយ។ ពាក្យនេះ ប្រើសម្រាប់សម្គាល់តែអ្នកបម្រើឬខ្ញុំបម្រើព្រះ ព្រះមហាក្សត្រ ព្រាហ្មណ៍ ព្រះសង្ឃ ឬមន្ត្រីធំជាដើម ពោលគឺសំដៅដល់អ្នកធ្វើកិច្ចការងារនៅក្នុងប្រាសាទ វត្តអារាម ឬរាជវាំងជាដើម។ លុះមកដល់សម័យកណ្ដាល ទើបយើងសង្កេតឃើញនៅក្នុងសិលាចារឹកនា

---

១៣ ឡុង សៀម ២០០០: 2G។

១៤ ជាសំណេរដែលមិនមាននៅក្នុងវចនានុក្រមខ្មែរ។

១៥ ពាក្យនេះ មានមនុស្សខ្មែរមួយចំនួននិយាយខ្ចីដោយបាត់សូរ [ផ] នៅខាងដើម។

១៦ គួរបញ្ជាក់ផងដែរថាពាក្យ «អង្គុយ» មានពាក្យឫស «គុយ» ដ្បិតនៅក្នុងភាសាខ្មែរបុរាណ មានពាក្យ «អង្គុយិ» និង «បង្គុយិ» និងនៅក្នុងភាសាទំនើប មានពាក្យ «អង្គុយ» និង «បង្គុយ» ដែលនាំយើងអាចសន្និដ្ឋានបានថាពាក្យទាំងពីរនេះ មាន «គុយិ» (ខ្មែរបុរាណ) ឬ «គុយ» (ខ្មែរទំនើប) ជាឫស។

១៧ ករណីពាក្យ « ស្ទូ > ទ្បូ, ស្ទា > ទ្បា, ស្ទាប់ > ទ្បាប់, ស្ទែង > ទ្បែង » ច្រើនសង្កេតឃើញភាគច្រើននៃអ្នកស្រុកមួយផ្នែកនៃខេត្តកំពង់ធំ កំពង់ចាម និងក្រចេះ។ មានអ្នកស្រាវជ្រាវខ្លះយល់ថាករណីនេះ ជាការលេបសូរព្យញ្ជនៈដើមព្យាង្គ ប៉ុន្តែខ្ញុំយល់ថាជាការនិយាយពាក្យឫសទៅវិញ។ យ៉ាងនេះក្ដី ឧទាហរណ៍ទាំងនេះសុទ្ធតែអាចជួយគាំទ្រសម្មតិកម្មសម្រាប់ពាក្យ ខ្ញុំ > ញុំ បានដែរ ទោះជាក្នុងករណីទីមួយឬទីពីរ ក៏ដោយចុះ។

១៨ ត្រូវនឹងភាសាអង់គ្លេសថា «aphaeresis/aphesis» និងភាសាបារាំងថា «aphérèse»។ សូមអាន៖ https://www.facebook.com/NCKLCambodia/photos/2777132879205338។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ប្រាសាទអង្គរវត្ត ចាប់ផ្តើមឃើញប្រើពាក្យនេះហៅខ្លួន ជាសព្វនាមបុរសទីមួយ។ ខាងក្រោមនេះជាឃ្លាឧទាហរណ៍ដកស្រង់ឃ្លាមានពាក្យ «ខ្ញុំ» ពីសិលាចារឹកគ្រប់សម័យកាល៖

| សម័យកាល | ឃ្លាឧទាហរណ៍ | ប្រែសម្រួល |
|---|---|---|
| មុនអង្គរ | **ក្ញុំ**អំនោយិម្រតាញតវ្រះ (K. ៦៖ ប. ៣) | ខ្ញុំបម្រើជាអំណោយរបស់ម្រតាញថ្វាយចំពោះព្រះ |
| | **ក្ញុំ**វ្រះកម្រតាងអញត្រីអាម្រាតកេគ្វរ បុន្យបោញក្ឫស្ណទត្ត (K. ៨៖ ប. ១) | ខ្ញុំបម្រើរបស់ព្រះកម្រតាងអញស្រី អាម្រាតកេស្វរ (ជា)បុណ្យរបស់ បោញក្រឹស្ណទត្ត |
| | **ក្ញុំ**តសិ (K. ៣០៖ ប. ១០) | ខ្ញុំបម្រើ(ភេទ)ប្រុស |
| | **ក្ញុំ**តកន្តៃ (K. ៧៦៖ ប. ៣) | ខ្ញុំបម្រើ(ភេទ)ស្រី |
| អង្គរ | រិ**ខ្ញុំ**កម្រតេងជគតិមនិតបស្វិឝិវ ស្ថានទុញនុទ្រវ្យ (K. ១៩៥៖ ប. ១៤) | រីខ្ញុំបម្រើរបស់ព្រះកម្តេងជគត (គឺ) តបស្វីសិវស្ថាន ទិញដោយទ្រព្យ |
| | **ខ្ញុំ**មនិវបាឱយិបរិគ្រោះតតេងឧមា (K. ២១៦ត្បូង៖ ប. ៣៧-៣៨) | ខ្ញុំបម្រើដែលរបាឱ្យដល់តេងឧមា |
| | តៃកន្អៀន តៃខ្មៅ **ខ្ញុំ**លោញវាម (K. ២២០ជើង៖ ប. ១០-១១) | នាងកន្អីន នាងខ្មៅ (ជា)ខ្ញុំ បម្រើរបស់លោញវាម |
| កណ្តាល | ទេព្វយេង**ខ្ញុំម**រព្ទកស្មារតិ (IMA១៧៖ ប.១៨-១៩) | ទើបយើងខ្ញុំរលឹកស្មារតី |
| | **ខ្ញុំម**ក្រាប៉្បក្រោម្មព្រះបាទ អព្ភិវាទ វរវន្ទី គិតថ្វ្យទៅព្រះត្រី រត្នត្រៃយ ត្រីក្កាល្វា (IMA៣៨៖ ប. ២) | ខ្ញុំក្រាបក្រោមព្រះបាទ អភិវាទវរវន្ទី គិតថ្វាយទៅព្រះស្រី រតនៈត្រៃស្រី កាលា។ |
| | ថ្វ្យហេ្យ**ខ្ញុំ**ទូលផ្តិង (IMA៣៨៖ ប. ៥) | ថ្វាយហើយខ្ញុំទូលប្តឹង |

(នៅមានត)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# បញ្ជីឯកសារយោង

ក្រុមប្រឹក្សាជាតិភាសាខ្មែរ

២០២០. https://www.facebook.com/NCKLCambodia/photos/2777132879205338

មាស សុភាព

២០២១. "ខ្ញុំ" ក្នុងសិលាចារឹកខ្មែរ. https://ams.com.kh/khmercivilization/detail/2493

ឡុង សៀម

២០០០. វចននានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨). ពេជពុម្ពភ្នំពេញ។

វចនានុក្រមខ្មែរ

១៩៦៨. វចនានុក្រមខ្មែរ ភាគ២. វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

Jenner, P. N.

2009[a]. *A dictionary of pre-Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.

2009[b]. *A dictionary of Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.

2011. *A dictionary of Middle Khmer*. Pacific linguistics, Research School of Pacific and Asian Studies, The Australian National University.

Nai Tun Way

2012. *A Dictionary of The Mon Inscription*. Tech Promotion & Advertising Co., Ltd.

# បញ្ជីរូបភាព



សិលាចារឹក K. ១០៣០ សម័យមុនអង្គរ



សិលាចារឹកនគរវត្តលេខ១៧ សម័យកណ្តាល

អត្ថបទដោយៈ ហ៊ុន ឈុនតេង



សិលាចារឹក K. ២១៤២ សម័យអង្គរ

អត្ថបទដោយៈ ហ៊ុន ឈុនតេង